**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស/បកប្រែជាភាសាខ្មែរ
កាលបរិច្ឆេទឯកសារ: ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Apr-2013, 15:14
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីការស្នើសុំឲ្យទទួលយកភស្តុតាងកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី & ឯកសារផ្សេងទៀត**
**(ភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ & សម្ងាត់បំផុត)**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**
ពេជ អង្គ
Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន ស៊ុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ អុត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**
ជា លាង
Andrew T. CAYLEY

គង់ ពិសី
យ៉ុង ផានិត
សំ សុគង់
វ៉េន ពៅ
ទី ស្រ៊ីនណា
គង់ ផល្លៈ
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Philippine SUTZ
Beini YE

យ៉េត ចរិយា
William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី
នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ
Victor KOPPE

អាង ឧត្តម
Michael G. KARNAVAS

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN
Jacques VERGES

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

## I. សេចក្តីផ្តើម

1. សារណានេះឆ្លើយតបជាចម្បង ទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងដែលមាននៅក្នុងឯកសារ E96/7 និង E223/2,[1] ប៉ុន្តែក៏ឆ្លើយតបទៅនឹងសេចក្តីសម្រេចមួយចំនួនកាលពីពេលថ្មីៗ និងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងបញ្ហានៃភ័ស្តុតាងដែលត្រូវបានស្នើសុំដាក់ ឬដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបញ្ហាពាក់ព័ន្ធស្តីពីការបកប្រែទាន់ពេលវេលានៃឯកសារទាំងនេះ។ តាមរយៈសារណានេះ ដើមបណ្តឹងរដ្ឋប្បវេណីព្យាយាមផ្តល់សេចក្តីបញ្ជាក់ជូនអង្គជំនុំជម្រះស្តីពីចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលពួកគាត់ស្នើសុំដាក់ជាភ័ស្តុតាង ព្រមទាំង រៀបរាប់អំពីផែនការជាក់លាក់មួយ ដែលធានាបានថាឯកសារផ្សេងៗទាំងអស់ដែលពួកគាត់ស្នើសុំដាក់ ជាភ័ស្តុតាងនឹងមានជូនអង្គជំនុំជម្រះ និងភាគីនៅមុនពេលបិទសវនាការដេញដោលភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១។

2. ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីនៅតែជឿជាក់ថាគ្រប់ភស្តុតាងទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងសំណុំរឿងគួរតែទទួលយកមកពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីចេញសាលក្រមសម្រាប់ករណីបច្ចុប្បន្ននេះក្តី ក៏យើងខ្ញុំបានប្រឹងប្រែងគោរពតាមការណែនាំរបស់អង្គជំនុំជម្រះដែលតម្រូវឱ្យមានការកាត់បន្ថយចំនួនឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវដាក់ជាភ័ស្តុតាង។ ដោយយោងទៅលើការវិវឌ្ឍន៍គួរឱ្យកត់សម្គាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីភ័ស្តុតាងជាលាយលក្ខណ៍អក្សរដូចបញ្ជាក់លម្អិតខាងក្រោម ដើមបណ្តឹងរដ្ឋប្បវេណីទទូចសុំឱ្យអង្គជំនុំជម្រះថ្លឹងថ្លែងផលប្រយោជន៍នៃប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលមានចំណែករបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ជាមួយនឹងការរួមចំណែកដែលថាភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើអាចជួយបញ្ជាក់ការពិតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកំពុងស្ថិតក្រោមការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការចូលរួមប្រកបដោយ

[1] *សូមមើល* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, **E96/7**, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (អំណេះតទៅហៅថា "សេចក្តីសម្រេចលើ កំណត់ហេតុស្តាប់ចម្លើយ"); និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសវនាការដេញដោលលើឯកសារពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភ័ស្តុតាងគាំទ្រ (ឯកសារ E223) ឯកសារលេខ **E223/2**, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ (អនុស្សរណៈស្តីពីគំរូតំណាង)។

អត្ថន័យនៅចំពោះមុខ អ.វ.ត.ក (តាមរយៈការធានាបានថាសក្ខីកម្មពាក់ព័ន្ធបំផុត និងមានតម្លៃជាភស្តុតាងរបស់ពួកគាត់ ត្រូវបានអង្គជំនុំជម្រះពិនិត្យពិចារណា) និងគោលការណ៍ជាសារវ័ន្តដែលធានាថាសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានគោរពនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីទាំងនេះ[2]។

3. នៅដើមដំបូង ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថាយោងទៅលើការធ្វើមោឃភាពកាលពីពេលថ្មីៗ របស់អង្គជំនុំជម្រះតុលាការកំពូលទៅលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២[3] និងការវាយតម្លៃឡើងវិញអំពីបញ្ហានេះរបស់អង្គជំនុំជម្រះសាលាដំបូង ពួកគាត់សូមរក្សាសិទ្ធិដើម្បីដាក់បន្ថែមពីលើបញ្ជីឯកសារដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសារណានេះ និងដាក់ឯកសារបន្ថែមពីបញ្ជីឯកសារមុនៗនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើវិសាលភាពនៃកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន ត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលធាតុផ្សំនានាដែលកាលពីពេលមុន ពុំមែនជាផ្នែកមួយនៃសំណុំរឿង ០០២/០១។

## II. ប្រវត្តិនីតិវិធី

4. កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើចម្លើយជាលាយលក្ខណ៍អក្សរ ដែលក្នុងនោះខ្លួនបានណែនាំឱ្យភាគីដែលបានស្នើសុំដាក់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកនៅចំពោះមុខអង្គជំនុំជម្រះ *ក្នុងចំណោមប្រការផ្សេងៗ* ពិនិត្យមើលឯកសារទាំងនេះ ឡើងវិញនៅក្នុងបញ្ជីពាក់ព័ន្ធរបស់ពួកគាត់ ដោយអនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីសម្រេចនេះ បញ្ជាក់បន្ថែមអំពីគោលបំណងជាភស្តុតាងសម្រាប់ឯកសារនីមួយៗ ឬប្រភេទនៃឯកសារនីមួយៗ និងពិចារណាអំពីការកំហិតចំនួនឯកសារដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រឹមឯកសារគំរូតំណាង[4]។

5. កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីសម្រេចលើចម្លើយជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះ និងសេចក្តីណែនាំនាពេលបន្ទាប់របស់អង្គជំនុំជម្រះទៅភាគីដើម្បីបង្ហាញអំពីចម្លើយជាលាយលក្ខណ៍អក្សរទាំងនោះ ពីក្នុងបញ្ជីឯកសាររបស់ពួក

---

[2] វិធាន ២១ (១) (គ) វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) អ.វ.ត.ក ថ្ងៃទី៣ ខែ សីហា ឆ្នាំ ២០១១។

[3] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០០១ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[4] សេចក្តីសម្រេចលើ កំណត់ហេតុស្តាប់ចម្លើយ, កថាខណ្ឌ ៣៥។

គាត់ដែលត្រូវបានដាក់កាលពីខែ មេសា ឆ្នាំ ២០១១ ដែលពួកគាត់ស្នើសុំដាក់ពាក់ព័ន្ធ នឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី ២[5]។ ក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗដែលត្រូវបានលើកនៅក្នុងសារណានេះ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថាខ្លឹមសារនៃភ័ស្តុតាងដែលមាន នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរនៅតែបន្តស្ថិតនៅចំពោះមុខអង្គជំនុំជម្រះទាំងមូល ហើយដើមបណ្តឹងរដ្ឋប្បវេណីនឹងបន្តដាក់ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ ចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធី ពិសេសផ្ទួបជាមួយការសួរដេញដោលដោយផ្ទាល់មាត់[6]។ ថ្វីបើមានទឡ្ហីករណ៍ទាំងនេះក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីក៏បានរក្សាសិទ្ធិដើម្បី ដាក់គំរូតំណាងនៃចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ[7]។

6. កាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈរបស់ខ្លួន ឯកសារ E223/2 ដែលបានលើកឡើងអំពីសវនាការលើឯកសារនាពេលខាងមុខ និងការកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ ដែលក្នុងនោះខ្លួនបានស្នើសុំភាគី "បញ្ជាក់ថាតើឯកសារបន្ថែមណាខ្លះ ពីក្នុងបញ្ជីឯកសារដើមរបស់ខ្លួន (*ពោលគឺ* ខែ មេសា ឆ្នាំ ២០១១) ដែលពួកគាត់ស្នើសុំដាក់ទាក់ទងនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន និងទួលពោធិជ្រៃ មិនឱ្យហួសថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២"[8]។ នៅក្នុងអនុស្សរណៈដដែលនេះ អង្គជំនុំជម្រះក៏បានណែនាំឲ្យសហមេធាវីនាំមុខ "កាត់បន្ថយចំនួននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់ស្នើសុំដាក់ដើម្បីធានាបានថាមានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលអាចមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមថ្ងៃ សុក្រ ទី ២៨ ខែ កុម្ភៈ ឆ្នាំ

[5] សូមមើល សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ E208/3 និងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E96/7 ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី ១ និងទី ២, **E208/4**, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

[6] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ៩-១៥ និង ៤៤-៤៦។

[7] *ដូចឯកសារយោងខាងលើ* សេចក្តីសន្និដ្ឋាន កថាខណ្ឌ (ឃ) ទំព័រ ១៦។

[8] អនុស្សរណៈរបស់ អង្គជំនុំជម្រះសាលាដំបូងស្តីពីសវនាការលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំកំណត់អត្តសញ្ញាណពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (E208/4) និងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំកែសម្រួលបញ្ជីភ័ស្តុតាងគាំទ្រ (E223), **E223/2**, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ៤។

២០១៣ [ក្រោយមកត្រូវបានកែតម្រូវទៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣] ប៉ុណ្ណោះ ត្រូវបានស្នើសុំដាក់ជាភ័ស្តុតាង"[9]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបង្គាប់ឱ្យសហមេធាវីនាំមុខបញ្ជាក់ថាតើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលខ្លួនស្នើសុំដាក់ជាភ័ស្តុតាង ក្នុងទម្រង់ជាពាក្យសុំគំរូតំណាងរបស់ខ្លួន និងនៅក្នុងធ្វើដូច្នេះ ផ្តល់"ព័ត៌មានផ្សេងៗទាំងអស់ដូចដែលអង្គជំនុំជម្រះបានស្នើសុំនៅក្នុងឯកសារ E96/7 កថាខណ្ឌ ៣៥"[10]។

7. នៅថ្ងៃទី២៨ កុម្ភៈ ២០១៣ សហព្រះរាជអាជ្ញាបានស្នើនូវនីតិវិធីដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការទទួលយកឯកសារដែលមិនទាន់ត្រូវបានបកប្រែជាបីភាសារបស់ អ.វ.ត.ក.[11]។ សហព្រះរាជអាជ្ញាបានលំអិតហើយបានស្នើសុំទៅកាន់អង្គជំនុំជម្រះសាលាដំបូងឱ្យផ្អែកទៅលើយុត្តិសាស្ត្ររបស់អ.វ.ត.ក. និងការអនុវត្តអន្តរជាតិដើម្បីឈានដល់សេចក្តីសម្រេចទាមទារឱ្យមានការបកប្រែនៅក្នុងដំណើរការនីតិវិធីបច្ចុប្បន្ន។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានកំណត់ពីនីតិវិធីដែលនឹងផ្តល់ឱកាសឱ្យជនជាប់ចោទកំណត់ពីឯកសារដែលមិនទាន់បានបកប្រែ ហើយដែលខ្លួនមិនអាចយល់បាន និងឱកាសសម្រាប់សហព្រះរាជអាជ្ញាដើម្បីឆ្លើយតប និងចាត់ចែងការបកប្រែសមស្រប[12]។

## III. ការពិភាក្សា

### *ក. ចម្លើយជាលាយលក្ខណ៍អក្សរដែលត្រូវបានដាក់បន្ទាប់ពីមានសេចក្តីសម្រេច E96/7*

8. តបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងឯកសារ E96/7 និងសេចក្តីណែនាំជាបន្តបន្ទាប់នៅក្នុងឯកសារ E223/2 ដូចដែលបានកត់សម្គាល់ខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់នៅក្នុងឧបសម្ព័ន្ធ ១ និង ១(ក) នៃឯកសារនេះនូវ **គំរូតំណាងមួយនៃចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែល*ពុំទាន់បាន* ផ្តល់ចម្លើយដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ** ក្នុងសំណុំរឿង ០០២/០១ ដោយរួមបញ្ចូលទាំងចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី៖

---

[9] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១២។

[10] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១៣។

[11] សំណើររបស់សហព្រះរាជអាជ្ញាសុំបង្កើតនីតិវិធីទាក់ទងនឹងការទទួលយកឯកសារដែលមិនទាន់បានបកប្រែជាគ្រប់ភាសារបស់អ.វ.ត.ក. លេខ E223/2/6 ចុះថ្ងៃទី២៨ កុម្ភៈ ២០១៣។

[12] សូមមើល កថាខ័ណ្ឌ ២៧-២៨។

a) ដែលត្រូវបានបង្ហាញនៅក្នុងសវនាការដេញដោលលើឯកសារសំខាន់ៗពីសំណាក់ភាគី

b) ត្រូវបានប្រើប្រាស់ក្នុងអំឡុងការសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញពីសំណាក់ភាគី

c) ដែលត្រូវបានស្នើសុំឱ្យផ្តល់សក្ខីកម្មពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែពុំទាន់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្ម[13]

d) ដែលត្រូវបានយកដោយ ក.ស.ច.ស នៅក្នុងទម្រង់នៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និង

e) ដែលត្រូវបានជ្រើសរើសដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់បញ្ចូលក្នុងគំរូតំណាងនេះ ដោយផ្អែកលើភ័ស្តុតាងដែលមាននៅក្នុងនោះ

9. នៅខណៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថាភ័ស្តុតាងទាំងអស់ ដែលមាននៅក្នុងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគួរតែរក្សាទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះ តែស្ថិតក្នុងបរិបទនៃការដាក់ពាក្យស្នើសុំទាំងនេះជាភ័ស្តុតាង និងការគោរពតាមការណែនាំរបស់អង្គជំនុំជម្រះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានធ្វើការជ្រើសរើសក្នុងចំនោមនោះ នូវឯកសារដែលទាក់ទងនឹងការកត់សម្គាល់ឃើញអំពីអង្គហេតុដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដូចដែលបានធ្វើកន្លងមក ព្រមទាំងភ័ស្តុតាងដែលទាក់ទងនឹងការបង្ហាញពីគោលនយោបាយទាំងប្រាំ ដូចមានកំនត់ក្នុងកថាខ័ណ្ឌ ១៥៦-១៥៩ នៃដីកាដំណោះស្រាយ[14]។

10. **ឧបសម្ព័ន្ធ ១ និង ១(ក)** មានចម្លើយជាលាយលក្ខណ៍អក្សរសរុបចំនួន ៥២២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងទម្រង់ជាទម្រង់ព័ត៌មានជនរងគ្រោះ ចម្លើយបន្ថែម កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និងការរៀបរាប់ផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីបទពិសោធន៍របស់ពួកគាត់ និង

---

[13] មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ថាវានៅមានភាពមិនច្បាស់លាស់នៅឡើយថាតើដើមបណ្តឹងរដ្ឋប្បវេណីរូបណាខ្លះនឹងត្រូវកោះអញ្ជើញឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលចុងក្រោយ។ អាស្រ័យហេតុនេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បញ្ចូលកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានស្នើឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដែលមិនទាន់បានផ្តល់សក្ខីកម្ម រួបទាំងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានពន្យាពេល និងគ្រោងពេលដើម្បីផ្តល់សក្ខីកម្ម។

[14] ដីការដំណោះស្រាយសំនុំរឿង ០០២ លេខ D427 ចុះថ្ងៃទី១៥ កញ្ញា ២០១០។

ភ័ស្តុតាងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ។ សម្រាប់ឯកសារនីមួយៗដែលមានក្នុង**ឧបសម្ព័ន្ធ ១ និង ១(ក)** ព័ត៌មានត្រូវបានផ្តល់ទាក់ទងនឹងលេខឯកសារ ចំនងជើងឯកសារ ដំណាក់កាលជំនុំជម្រះ គោលបំណងជាភ័ស្តុតាង និងចំនុចពាក់ព័ន្ធនឹងការចោទប្រកាន់។ ឯកសារនីមួយៗក្នុងចំណោមឯកសារទាំងឡាយដែលមាននៅក្នុងបញ្ជីនេះធ្លាប់ត្រូវបានស្នើឡើងនៅក្នុងបញ្ជីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១[15]។ ជាងនេះទៀត ឯកសារទាំងអស់ដែលបានចុះបញ្ជីនៅក្នុងឧបសម្ព័ន្ធ ១ ស្ថិតនៅក្នុងសំណុំរឿង ហើយភាគីអាចពិនិត្យមើលបានតាមរយៈ Zylab ស្ទើរតែនៅគ្រប់ករណីទាំងអស់[16]។ ក្នុងករណីដែលឯកសារទាំងនេះពុំមានតាមរយៈប្រព័ន្ធ Zylab ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការសាកសួរចាំបាច់ និងរង់ចាំការកំណត់ចុងក្រោយអំពីស្ថានភាពនៃសេចក្តីបង្គាប់រក្សាការពារ ដើម្បីដឹងថាតើឯកសារនោះនឹងត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ឬក៏ត្រូវដកចេញពីបញ្ជីតាមការសមស្រប។ ក្នុងករណីបែបនេះ សេចក្តីលម្អិតក្រៅពីលេខឯកសារដែលអង្គជំនុំជម្រះសាលាដំបូងស្នើសុំអាចត្រូវបានរកឃើញនៅក្នុង **ឧបសម្ព័ន្ធ ១ (ក)**។

11. ពាក់ព័ន្ធនឹងចំណុចនៃ**ការបកប្រែ** ចាប់តាំងពីពេលអង្គជំនុំជម្រះបានចេញ E223/2 ដើមបណ្តឹងរដ្ឋប្បវេណីបានយល់ និងបានព្យាយាមយកចិត្តទុកដាក់ចំពោះសេចក្តីណែនាំរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការបកប្រែចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់បញ្ជីឯកសារដែលត្រូវបានកាត់បន្ថែម និងកែសម្រួលនេះ។ ត្រង់ប្រការនេះ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការកត់សម្គាល់ថាពួកគាត់បានធ្វើឱ្យមានការវិវឌ្ឍគួរឱ្យកត់សម្គាល់នៅក្នុងការទទួលបានការបកប្រែឯកសារទាំងប៉ុន្មាន ដែលពួកគាត់ដាក់បញ្ចូលក្នុងបញ្ជីរបស់ពួកគាត់ ដោយមានការពិគ្រោះជាមួយ និងតាមរយៈកិច្ចខិតខំខ្នះខ្នែងរបស់អង្គភាពបកប្រែភាសា និង

---

[15] *សូមមើល ឧទាហរណ៍ ឧបសម្ព័ន្ធដែលត្រូវបានកែសម្រួល ៧ (ក)* (iii): ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, **E109/2.2**, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១១។ *សូមមើលផងដែរ* បញ្ជីដែលបានកែសម្រួលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃឯកសារ និងភ័ស្តុតាងផ្តោតលើពាក់ព័ន្ធនឹងចំណុចអង្គហេតុចំនួន៤ដំបូងដែលត្រូវធ្វើសវនាការ ឯកសារលេខ **E109/2**, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ១២ (ដែលពន្យល់ថាខ្លឹមសារទាំងស្រុងនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងឯកសារឧបសម្ព័ន្ធដែលភ្ជាប់នឹងឯកសារ D22 ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនេះ។.

[16] ឯកសារដែលពុំអាចពិនិត្យមើលបាននៅ Zylab គឺជាឯកសារដែលនៅមានចំណាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត។ ឯកសារទាំងនេះមាននៅក្នុង**ឧបសម្ព័ន្ធ ១** ដោយមានតែលេខឯកសារប៉ុណ្ណោះ និងនៅក្នុងបញ្ជីឯកសារយោងសម្ងាត់បំផុត **ឧបសម្ព័ន្ធ ១(ក)**។ ចំពោះឯកសារសម្ងាត់បំផុត ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការពិភាក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់ (ដូចជា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី WESU ជាដើម) ហើយកំពុងរង់ចាំការកំនត់ចុងក្រោយអំពីស្ថានភាពនៃសំណើសុំវិធានការណ៍ការពារ។ ប្រសិនបើសមស្រប ពួកគាត់នឹងស្វែងរកការធ្វើចំណាត់ថ្នាក់ឯកសារទាំងនេះឡើងវិញ បើមិនដូច្នោះ ឯកសារទាំងនោះនឹងត្រូវដកចេញពីបញ្ជី។

អង្គភាពបណ្ណសារ។ យ៉ាងណាមិញ ដើមបណ្តឹងរដ្ឋប្បវេណី (និងអង្គភាពបកប្រែភាសា) បានជួបប្រឈមការលំបាកធំៗនៅក្នុងការបញ្ចប់ជាស្ថាពរនូវការបកប្រែឯកសារទាំងអស់នេះ។

12. ក្រៅពីពេលវេលាដែលខ្លួនបានចំណាយដើម្បីកំណត់អត្តសញ្ញាណឯកសារពាក់ព័ន្ធ និងការបកប្រែដែលចាំបាច់នៅក្នុងពិគ្រោះយោបល់ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ រូប ដើមបណ្តឹងរដ្ឋប្បវេណីបានជួបប្រឈមនឹងការលំបាកមួយដែលភាគច្រើននៃឯកសារដែលពួកគាត់ស្នើសុំបកប្រែ មានទាំងសំណើបកប្រែដែលមានស្រាប់ (ជាលទ្ធផលនៃសំណើបកប្រែកាលពីពេលមុនដែលមានទំហំធំ)[17] ឬសំណើបកប្រែដែលត្រូវបានលុបចោល ដែលមានរួចហើយនៅក្នុងប្រព័ន្ធ (ដែលធ្វើឡើងមួយផ្នែកធំដោយ CMS ដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធដែលមានកម្រិត)។ ក្រោមស្ថានភាពទាំងនេះ ដើមបណ្តឹងរដ្ឋប្បវេណីពុំអាចបញ្ចូល ឬកែប្រែសំណើបកប្រែចំពោះឯកសារសំខាន់ៗ ដែលត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់តាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យបកប្រែឡើយ។ ប៉ុន្តែ ពួកគាត់ត្រូវតែបញ្ចូល និងកែប្រែសំណើនានាតាមរយៈមធ្យោបាយផ្សេងៗមួយចំនួន។ ជាការសាមញ្ញបំផុតនេះពាក់ព័ន្ធនឹងការរៀបចំតារាង spreadsheet លម្អិតមួយសម្រាប់ ឯកសារនីមួយៗ និងការបកប្រែភាសានីមួយៗ ដែលត្រូវបានស្នើសុំសម្រាប់ឯកសារនោះដែលបន្ទាប់មកត្រូវបានបញ្ជូនទៅអង្គភាពបណ្ណសារដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធអ៊ីនធឺហ្វេសដោយផ្ទាល់ដៃ។ កាលៈទេសៈនេះព្រមទាំងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យបកប្រែបានរារាំងដើមបណ្តឹងរដ្ឋប្បវេណីពីការដាក់បញ្ចូលជាថ្មី/ការផ្តួចផ្តើមជាថ្មីនូវសំណើនានា ឬការកែប្រែការណែនាំពាក់ព័ន្ធនឹងសំណើទាំងនេះផ្ទាល់តាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យបកប្រែ (translation interface) ។

13. ថ្វីបើដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការស្និតរមួតជាមួយអង្គភាពបកប្រែភាសា និងអង្គភាពបណ្ណសារដើម្បីលើកឡើង និងធ្វើការជុំវិញការដាក់កំហិតទាំងនេះក៏ដោយ ក៏ខ្លួនបានបង្កើនគួរឱ្យកត់សម្គាល់នូវវិធានការនិងពេលវេលាដែលចាំបាច់ដើម្បីធ្វើ និងចាត់ចែងសំណើបកប្រែនីមួយៗសម្រាប់ផ្នែកពាក់ព័ន្ធទាំងអស់(LCLS, ITU and RAU)។ បន្ថែមពីលើនេះ ដូចដែលអង្គជំនុំជម្រះទំនងជាបានជ្រាប អង្គភាពបកប្រែភាសាបានជួបប្រទះឧបសគ្គរបស់ខ្លួននៅក្នុងការបំពេញតម្រូវការនៃការបកប្រែ ពិសេសការបកប្រែពីភាសាខ្មែរទៅបារាំង និងពីភាសាបារាំង ទៅភាសាខ្មែរ។ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការស្និតរមួតជាមួយអង្គភាពបកប្រែភាសាដើម្បីដោះស្រាយបញ្ហានេះ រួមទាំងការដាក់បញ្ចូលជាថ្មី និងការកែប្រែសំណើសុំបកប្រែ ដើម្បីឱ្យបាន

[17] សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបង្កើតផែនការមួយដោយពិគ្រោះជាមួយ ITU និង RAU ដើម្បីធានាបានថាការបកប្រែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ឆ្នាំ ២០១២-២០១៣។ ផ្នែកសហមេធាវីនាំមុខបានប្រគល់ទៅ ITU និង RAU នូវតារាងបញ្ជាក់អំពីសំណើទាំងនេះ ដែលត្រូវបានដាក់ក្នុងប្រព័ន្ធដោយ RAU នៅចុងខែ សីហា ឆ្នាំ ២០១២។

ចប់សព្វគ្រប់ដោយឆាប់រហ័ស ប៉ុន្តែគួរកត់សម្គាល់ថាភាគច្រើននៃសំណើបកប្រែដែលពុំពេញលេញសម្រាប់ឯកសារនានានៅក្នុង**ឧបសម្ព័ន្ធ ១** ទាក់ទងនឹងការបកប្រែរវាងភាសាខ្មែរ និងភាសាបារាំង។

14. យោងទៅលើការលំបាកទាំងនេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យឯកសារទាំងអស់ដែលមាននៅក្នុង **ឧបសម្ព័ន្ធ ១** នៅស្ថិតក្រោមការពិចារណាសម្រាប់ការដាក់ជាភ័ស្តុតាងពីសំណាក់អង្គជំនុំជម្រះ ហើយពេលកំណត់សម្រាប់ការបកប្រែជាបីភាសាផ្លូវការរបស់តុលាការគួរតែនៅពេលបញ្ចប់សវនការលើភ័ស្តុតាងនៃសំណុំរឿងបច្ចុប្បន្ន។

## *ខ. ឯកសារគ្រប់ប្រភេទដទៃទៀតដែលបានស្នើសុំ & សម្ភារៈទាំងអស់ដែលបានដាក់*

15. ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់សេចក្តីបង្គាប់ថ្មីៗបំផុតនេះរបស់អង្គជំនុំជម្រះស្តីពីអត្តសញ្ញាណនៃឯកសារនានាពាក់ព័ន្ធនឹងប្រភេទភ័ស្តុតាងដែលនៅសេសសល់ និងគោលជំហររបស់អង្គជំនុំជម្រះដែលថាគ្រប់ឯកសារទាំងអស់នេះត្រូវតែបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ត.ក[18]។ មិនខុសពីសហព្រះរាជអាជ្ញាឡើយ[19] និងអនុលោមតាមឯកសារ E223/2 ដើមបណ្តឹងរដ្ឋប្បវេណីយល់

[18] សូមមើល សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ **E185/1** ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១៦ (បញ្ជាក់ថា ភាគីនានាដែលស្នើសុំបង្ហាញឯកសារនៅពេលសវនាការត្រូវធានាឱ្យទាន់ពេលនូវឯកសារបកប្រែជាភាសាផ្លូវការបីភាសារបស់ អ.វ.ត.ក)។ និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់ ឯកសារ **E246/1** កថាខណ្ឌ ៣ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ (បញ្ជាក់ថា កាលបរិច្ឆេទថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ សម្រាប់ការបកប្រែឯកសារជាបីភាសាផ្លូវការរបស់ អ.វ.ត.ក អនុវត្តទៅលើ "*ឯកសារសម្ភារៈទាំងអស់ដែលត្រូវបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយក*" ហើយថា ភាគីទាំងអស់ត្រូវតែធានាថា "ភ័ស្តុតាងគ្រប់ប្រភេទទាំងអស់ដែលភាគីបានស្នើសុំ មានជាបីភាសានៅត្រឹមកាលបរិច្ឆេទថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ហើយឯកសារសម្ភារៈទាំងអស់ដែលភាគីនឹងបង្ហាញ អាចមានជាបីភាសាផ្លូវការនៅ អ.វ.ត.ក ចំពោះមុខអង្គជំនុំជម្រះ មុនពេលនៃការបញ្ចប់កិច្ចពិភាក្សាដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង 00២/0១") (សេចក្តីបញ្ជាក់បន្ថែម)។

[19] សូមមើល សំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺអំពី "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ ក៦-ក១១ និង ក១៤-ក២០ របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត" ឯកសារ **E185/1/1** កថាខណ្ឌ ៣ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២

ថាកាលបរិច្ឆេទថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ សម្រាប់ការបកប្រែយកមកអនុវត្តតែទៅលើប្រភេទឯកសារដែលបានកំណត់នៅក្នុងឯកសារ E96/7 និងក្រោយមកទៀតនៅក្នុងឯកសារ E223/2 ប៉ុណ្ណោះ។ ដូចដែលបានកត់សម្គាល់ពីមុន រហូតដល់ពេលដែលយើងបានទទួលសេចក្តីបង្គាប់បន្ថែមទៀតពីអង្គជំនុំជម្រះស្តីពីការបកប្រែ[20] ដើមបណ្តឹងរដ្ឋប្បវេណីពុំបានដឹងឡើយថា វាគឺជាគោលជំហររបស់អង្គជំនុំជម្រះដែលថាឯកសារទាំងអស់ដែលស្នើដាក់ជាភ័ស្តុតាង ត្រូវតែមានជាបីភាសាផ្លូវការរបស់អង្គជំនុំជម្រះ និងលើសពីនេះទៀត កាលបរិច្ឆេទត្រឹមថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ នោះ។

16. ដើមបណ្តឹងរដ្ឋប្បវេណីពិចារណាថា ទោះបីជាឯកសារ E131/1 កំណត់ថា "នៅពេលដែលភាគីបង្ហាញឯកសារណាមួយនៅក្នុងពេលសវនាការ ឯកសារគួរតែមានជាបីភាសាដែលប្រើប្រាស់ជាផ្លូវការនៅ អ.វ.ត.ក" ហើយថាបន្ទុកក្នុងការបកប្រែទាំងនេះត្រូវធ្លាក់ទៅលើភាគីយ៉ាងណាក៏ដោយ[21] ក៏ដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាការកែប្រែក្រោយមកទៀតទៅលើគោលការណ៍អនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ[22] មានន័យថានៅពេលដែលគោលការណ៍អនុវត្តបែបនេះត្រូវបានអង្គជំនុំជម្រះទទួលយកសម្រាប់ឯកសារជាក់លាក់មួយនោះ ការបកប្រែផ្នែកដែលពាក់ព័ន្ធនៃឯកសារនេះជាបីភាសារបស់តុលាការមិនយកមកអនុវត្តទៀតឡើយ។ នៅត្រឹមពេល

---

(កត់សម្គាល់ថា មុនពេលអង្គជំនុំជម្រះចេញឯកសារ E185/1 សហព្រះរាជអាជ្ញាយល់ថា អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែតម្រូវថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី (និងបណ្តឹង) ត្រូវបកប្រែជាបីភាសាផ្លូវការនៅត្រឹមកាលបរិច្ឆេទដូចដែលមានកំណត់នៅក្នុងឯកសារ E223/2) ។

[20] សូមមើល ឯកសារ **E246/1** កថាខណ្ឌ ៣ *ដូចយោងខាងលើ* ត្រង់កំណត់សម្គាល់ ១៨។

[21] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ឯកសារ **E131/1** ទំព័រ ៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ (សេចក្តីបញ្ជាក់បន្ថែម)។

[22] សូមមើល ឯកសារ **E246/1** កថាខណ្ឌ ៣ *ដូចយោងខាងលើ* ត្រង់កំណត់សម្គាល់ ១៨ (យោងមុនការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឲ្យភាគីនានាដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសវនាការផ្ទាល់មាត់ជាពីរភាសា ឬជួនកាលតែមួយភាសាផ្លូវការរបស់ អ.វ.ត.ក ប៉ុណ្ណោះ)។

ដែលអង្គជំនុំជម្រះបានបញ្ជាក់ថាការបកប្រែជាបីភាសាតម្រូវឱ្យមាននៅត្រឹមថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ សម្រាប់បណ្តុំឯកសារដ៏ធំទូលំទូលាយជាងដើមបណ្តឹងរដ្ឋប្បវេណីបានដឹងនោះវាយឺតពេលទៅហើយ និងមិនអាចឱ្យពួកគាត់មានលទ្ធភាពចាត់ចែងដំណើរការបកប្រែឯកសារទាំងនោះ តាមរយៈអង្គភាពបកប្រែភាសា (ITU) នៅត្រឹមកាលបរិច្ឆេទនោះបានទេ។

17. ទោះបីជាជាដើមបណ្តឹងរដ្ឋប្បវេណីមានទស្សនៈអំពីលក្ខខណ្ឌតម្រូវនៃការបកប្រែ រហូតមកដល់ពេលនេះយ៉ាងណាក៏ដោយ ក៏ពួកគាត់ខិតខំប្រឹងប្រែងប្រតិបត្តិតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ ដើម្បីធានានូវការបកប្រែឯកសារដែលស្នើដាក់ជាភស្តុតាងជាបីភាសាផ្លូវការរបស់ អ.វ.ត.កឱ្យបានទាន់ពេលវេលា។ នៅពេលបច្ចុប្បន្ននេះ ពួកគាត់កំពុងតែពិនិត្យប្រភេទឯកសារដទៃទៀតដូចខាងក្រោមនេះ ដែលឯកសារទាំងនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបញ្ជាក់អំពីប្រភេទនៃការបកប្រែឯកសារទាំងនេះ និងធ្វើសំណើសុំបកប្រែបន្ថែម ប្រសិនបើចាំបាច់៖

ក) ឯកសារដែលដាក់បញ្ចូលទៅក្នុងបញ្ជីឯកសារ និងវត្ថុតាង ដែលដាក់ជូនអង្គជំនុំជម្រះ[23]។

ខ) ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងពេលសវនាការលើឯកសារសំខាន់ៗ។

គ) ឯកសារដែលប្រើប្រាស់នៅក្នុងការសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ។ និង

ឃ) ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែល<u>*គ្មាន*</u>ផ្តល់សក្ខីកម្មផ្ទាល់មាត់។

[23] ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា ឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនេះ គឺជាកម្មវត្ថុនៃការពិភាក្សាដេញដោលរួចហើយ និងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចរាល់ហើយ។ សូមមើល ឧទាហរណ៍ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ **E190** ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២។ និងឯកសារ **E185/1** *ដូចយោងខាងលើ* ត្រង់កំណត់សម្គាល់ ១៨។

18. ទាក់ទិននឹងឯកសារនៅចំណុច (ឃ) ដើមបណ្តឹងរដ្ឋប្បវេណីគូសបញ្ជាក់ថាចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មផ្ទាល់មាត់រួចហើយនោះ មិនមែនជាកម្មវត្ថុនៃឯកសារ E96/7 ឬសេចក្តីបង្គាប់ដែលពាក់ព័ន្ធ និងសេចក្តីបង្គាប់ក្រោយៗមកទៀតរបស់អង្គជំនុំជម្រះឡើយ។ ដូច្នេះ ឯកសារទាំងនេះមិនត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ១ និង ១(ក)ឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីមានគោលជំហរថា មិនត្រឹមតែឯកសារទាំងនេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្តល់ឱកាសឲ្យភាគីដើម្បីធ្វើការជំទាស់ទៅនឹងឯកសារទាំងនេះទៀតផង ហើយនៅពេលដែលការជំទាស់ត្រូវបានបដិសេធ ឯកសារទាំងនេះត្រូវបានស្នើដាក់ជាភ័ស្តុតាង និងទទួលបានប្រភេទជា E3[24]។ ទាក់ទិននឹងការបកប្រែឯកសារទាំងនេះ នៅក្នុងករណីជាច្រើន ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានស្នើសុំការបកប្រែផ្នែកដែលពាក់ព័ន្ធនៃឯកសារទាំងនេះយ៉ាងហោចណាស់ជាពីរភាសា។ ពួកគាត់កំពុងតែរៀបចំបញ្ចប់ការពិនិត្យមើលឡើងវិញរបស់ពួកគាត់ និងធានានូវដំណើរការបកប្រែឲ្យទាន់ពេលវេលាជាបីភាសាផ្លូវការរបស់ អ.វ.ត.ក។

19. ក្នុងវិសាលភាពដែលអង្គជំនុំជម្រះពិចារណាថាប្រភេទឯកសារមួយចំនួន ឬទាំងអស់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១៧ ខាងលើត្រូវស្ថិតនៅក្រោមកាលបរិច្ឆេទថ្ងៃទី ៤ ខែ មីនា នោះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយសេចក្តីគោរពឲ្យអង្គជំនុំជម្រះសម្រេចថា ឯកសារទាំងអស់ប្រភេទនេះនឹងអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើឯកសារទាំងនេះត្រូវបានបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ត.ក នៅពេលបិទបញ្ចប់សវនាការក្នុងសំណុំរឿង ០០២/០១។ ផ្អែកទៅលើការវិភាគបឋមលើឯកសារទាំងនេះ ពួកគាត់ជឿជាក់ថាសំណើសុំបកប្រែដែលពាក់ព័ន្ធនឹង

---

[24] ទាក់ទិននឹងចំណុចក្រោយនេះ សូមមើលសារអេឡិចត្រូនិករបស់សហមេធាវីនាំមុខ ផ្ញើជូន Susan Lamb និងភាគីនានា ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងមានចំណងជើងថា "បញ្ហាបន្តទៀត ក្នុងឯកសារ E246/1" ដែលក្នុងនោះ ដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះដាក់លេខ E3 ចំពោះឯកសារទាំងនោះដែលបំពេញនូវលក្ខណៈវិនិច្ឆ័យ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះ និងមិនទាន់ត្រូវបានអង្គជំនុំជម្រះដាក់លេខបែបនេះឡើយ។

មានចំនួនតិចតួច ជាពិសេសបើប្រៀបធៀបជាមួយនឹងសំណើសុំបកប្រែរបស់ភាគីផ្សេងៗទៀត ហើយថាសំណើសុំបកប្រែទាំងនេះនឹងមិនដាក់បន្ទុកធ្ងន់ហួសហេតុទៅលើ ITU និង RAU ឡើយ។ ដើម្បីជួយដល់អង្គជំនុំជម្រះតទៅទៀតនៅក្នុងការចេញសេចក្តីសម្រេចលើសំណើនេះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង នូវសេចក្តីពិពណ៌នាលម្អិតនៃឯកសារទាំងអស់ដែលមាននៅក្នុងចំណងជើងនេះ ដែលឯកសារទាំងនេះបានស្នើដាក់ជាភស្តុតាងរួចហើយ ឬក៏ត្រូវបានស្នើសុំដាក់ជាភស្តុតាង ដោយមានប្រភេទនៃការបកប្រែរបស់ឯកសារទាំងនេះ និងកាលបរិច្ឆេទបញ្ចប់ការបកប្រែឯកសារទាំងនេះតាមការគ្រោងទុកនៅត្រឹម <u>ថ្ងៃសុក្រ ទី ១២ ខែ មេសា ឆ្នាំ ២០១៣</u> ដោយមានការពិភាក្សាជាមួយនឹង ITU។

**គ. សំណើសុំបកប្រែឯកសារ ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួមជាមួយនឹងការពិនិត្យសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលគ្រោងនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខ (ពុំទាន់ត្រូវបានកំណត់កាលបរិច្ឆេទនៅឡើយ)**

20. សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញជាច្រើននាក់ដែលត្រូវបានអង្គជំនុំជម្រះជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ នៅពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ។ ប្រសិនបើពុំមានភាពប្រាកដប្រជាថាតើ បុគ្គលទាំងនេះណាខ្លះដែលនឹងមកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះនោះ ដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពកំណត់អត្តសញ្ញាណជាមុនឱ្យបានសមស្របថាតើ សេចក្តីប្រកាសរបស់ដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលអាចយកមកប្រើប្រាស់ រួមជាមួយនឹងការពិនិត្យសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញមួយក្រុមធំនេះ។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមរក្សាសិទ្ធិដាក់សេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត នៅចំពោះមុខអង្គជំនុំជម្រះនាពេលក្រោយ រួមជាមួយនឹងការពិនិត្យសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលគ្រោងនឹងមកផ្តល់សក្ខីកម្មនាពេលខាងមុខ។

21. ក្នុងករណីដែលខ្លួនពិតជាចង់ស្នើសុំដាក់ឯកសារបែបនេះនៅចំពោះមុខអង្គជំនុំជម្រះមែននោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងគោរពតាមការអនុវត្ត ដែលត្រូវបានអង្គជំនុំជម្រះបង្កើតឡើងសម្រាប់អនុវត្តមកទល់ពេលបច្ចុប្បន្ន ពោលគឺ ១) ការដាក់ឯកសារណាមួយនៅក្នុងប្រព័ន្ធដាក់ឯកសារ (Interface)

ត្រូវធ្វើឡើងយ៉ាងហោចណាស់ឲ្យបាន ២៤ ម៉ោង មុនពេលចាប់ផ្តើមសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ និង ២) ត្រូវស្នើសុំការបកប្រែឯកសារនោះឲ្យបានទាន់ពេលវេលាយ៉ាងហោចណាស់ឲ្យបានទៅជាពីរភាសាសម្រាប់ប្រើប្រាស់នៅក្នុងពេលសួរដេញដោល។ លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងស្នើសុំឲ្យធ្វើការបកប្រែឯកសារនេះទៅជាបីភាសាផ្លូវការរបស់ អ.វ.ត.ក ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយពុំឲ្យហួសពេលបញ្ចប់កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០១។ ដើមបណ្តឹងរដ្ឋប្បវេណីធ្វើដូច្នេះដោយសារខ្លួនយល់ឃើញថា នៅពេលដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការសួរដេញដោលនោះ ភាគីទាំងអស់មានឱកាសលើកឡើងការជំទាស់ទៅនឹងឯកសារនៅក្នុងពេលនោះតែម្តង ហើយប្រសិនបើខ្លួនមិនលើកឡើងទេនោះ ឱកាសសម្រាប់ការតទល់ចំពោះមុខបែបនេះបានកន្លងផុត។

## ឃ. ភាពអាចទទួលយកបាន និងការផ្តល់តម្លៃនៃភ័ស្តុតាងលើឯកសារ

22. យោងតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង[25] ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ព័ត៌មានស្តីពីគោលបំណងនៃភ័ស្តុតាងនៅក្នុង**ឧបសម្ព័ន្ធ ១ និង ១(ក)** ដែលខ្លួនស្នើសុំដាក់ឯកសារនីមួយៗដូចមានរៀបរាប់នៅក្នុងបញ្ជីនៅចំពោះមុខអង្គជំនុំជម្រះ។ ម្យ៉ាងវិញទៀត ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ចំណុចនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលភ័ស្តុតាងនៅក្នុងសេចក្តីប្រកាសមានការពាក់ព័ន្ធ។ ក្នុងករណីដែលឯកសារទាំងនេះរួមបញ្ចូលភ័ស្តុតាងស្តីពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះ ដើមបណ្តឹងរដ្ឋប្បវេណីសូមគូសបញ្ជាក់ថាខ្លួនពុំដាក់ព័ត៌មាននេះដើម្បីបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទឡើយ ក៏ប៉ុន្តែខ្លួនដាក់ព័ត៌មាននេះដើម្បីគាំទ្រការប្រើប្រាស់ព័ត៌មាននេះទៅតាមច្បាប់អនុញ្ញាត ដូចមានចែងនៅក្នុងយុត្តិសាស្ត្រនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនានា និងដូចបានរៀបរាប់លម្អិតនៅក្នុងសេចក្តីសន្និដ្ឋានពីមុនៗ និងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[26]។ ករណីនេះរួមបញ្ចូលជាឧទាហរណ៍គោលបំណងនៃការបង្កើតគោលនយោបាយទូទៅ និងរចនាសម្ព័ន្ធ ព្រមទាំងប្រវត្តិអង្គហេតុនៃឧក្រិដ្ឋកម្ម។ ។

---

[25] *សូមមើល*ចំណុចខាងលើត្រង់កថាខណ្ឌ ៤។

[26] *សូមមើល* ឧ. ឯកសារ E96/7 ចំនុចខាងលើត្រង់កំណត់សម្គាល់លេខ ១ កថាខណ្ឌ ២១-២២ និងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី១-១៦ ឯកសារ E96/8 កថាខណ្ឌ ១៦-១៧។

23. ក្រៅពីព័ត៌មានដូចបានរៀបរាប់នៅក្នុង**ឧបសម្ព័ន្ធ ១ និង ១(ក)** ដែលគាំទ្រភាពអាចទទួលយកបាន និងតម្លៃនៃភ័ស្តុតាងនៃសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលពុំមានសក្ខីកម្មផ្តល់ជូនដោយចារីនោះ ដើមបណ្តឹងរដ្ឋប្បវេណីសូមរំលឹកឡើងវិញថាខ្លួនបានធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមួយចំនួនពីមុនៗដែលបានលើកឡើងអំពីប្រធានបទទាំងនេះ[27]។ ដើមបណ្តឹងរដ្ឋប្បវេណីសូមផ្តល់ព័ត៌មានដូចបានរៀបរាប់នៅក្នុង**ឧបសម្ព័ន្ធ ១ និង ១(ក)** ដើម្បីបញ្ជាក់អំពីមូលដ្ឋានខុសៗគ្នាសម្រាប់ការទទួលយកឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ។ ទោះបីជាយ៉ាងនេះក្តី ព័ត៌មាននេះពុំមែនមានត្រឹមតែប៉ុណ្ណេះនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីសូមរក្សាសិទ្ធិបញ្ជាក់ព័ត៌មានលម្អិតបន្ថែម ស្តីពីចំនុចទាំងនេះដើម្បីឆ្លើយតបទៅនឹងការជំទាស់របស់ភាគី និងដើម្បីគាំទ្រអង្គជំនុំជម្រះដែលបានផ្តល់តម្លៃលើភ័ស្តុតាងទាំងនេះនាពេលក្រោយ។

## IV. **សេចក្តីសន្និដ្ឋាន**

24. ដើមបណ្តឹងរដ្ឋប្បវេណីយល់ និងមានបំណងគោរពតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងពិនិត្យសម្រេចលើការបកប្រែឯកសារដែលត្រូវបានទទួលយកមកធ្វើជាភ័ស្តុតាង។ ដើមបណ្តឹងរដ្ឋប្បវេណីបានបង្កើតការវិវត្តគួរឱ្យកត់សម្គាល់ក្នុងទិសដៅនេះ ហើយសង្ឃឹមថាអង្គជំនុំជម្រះនឹងធ្វើការពិចារណាអំពីភាពជាក់លាក់ ដែលឯកសារបកប្រែទាំងនេះបានឆ្លើយតបទៅនឹងការណែនាំក្នុងពេលថ្មីៗនិងវឌ្ឍនភាពយ៉ាងច្រើននៅក្នុងការបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងឯកសារលេខ E96/7 E223/2 និង E246/1។ លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រយ៉ាងខ្លាំងក្លានូវហេតុផល និងនីតិវិធីដែលបានកំនត់ពីមុនដោយសហព្រះរាជអាជ្ញា ដើម្បីដោះស្រាយបញ្ហា

---

[27] *សូមមើល* ឧ. បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធ ៧ និង ៨) ឯកសារ E9/32 ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ E208/3 និងសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E96/7 ដោយរួមបញ្ចូលទាំងឧបសម្ព័ន្ធសម្ងាត់ទី១ និងទី២ ឯកសារ E208/4 ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។

បកប្រែឯកសារ និងស្នើសុំទៅកាន់អង្គជំនុំជម្រះឱ្យអនុម័តយកការអនុវត្តនោះ និងផ្តល់សិទ្ធិដូចគ្នា នៅក្នុងនីតិវិធីដល់សហមេធាវីនាំមុខ ដូចអ្វីដែលមានក្នុងគំរូរបស់សហព្រះរាជអាជ្ញា។

25. នៅពេលពិចារណាលើចំនុចដូចបានលើកឡើងខាងលើ ដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក) ទទួលយកសេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចបានរៀបរាប់នៅក្នុង**ឧបសម្ព័ន្ធ ១ និង ១(ក)** មកធ្វើជាភស្តុតាង និងកំណត់លេខសម្គាល់ឯកសារ E3 ចំពោះឯកសារនីមួយៗណាដែលពុំទាន់ត្រូវបានកំណត់លេខសម្គាល់នៅឡើយ។ និង

ខ) អនុញ្ញាតឱ្យដាក់ ឬ ទទួលយកឯកសារគ្រប់ប្រភេទដូចបានកំណត់អត្តសញ្ញាណនៅក្នុងកថាខណ្ឌ ១៧ នៅចំពោះមុខអង្គជំនុំជម្រះ (នៅក្នុងករណីដែលការកំណត់បែបនេះបានធ្វើឡើងរួចរាល់ហើយនោះ) ហើយបញ្ហានៃការបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ត.ក. ត្រូវបានដោះស្រាយស្របតាមនីតិវិធីដែលសហព្រះរាជអាជ្ញាបានស្នើឡើង។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារនេះដោយក្តីគោរពពីយើងខ្ញុំ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៣ | ពេជ អង្គ<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |